ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..១៧៦..សហវ.ក.ប្រក.-ខរ៉េសេ

# ប្រកាស
# ស្តីពី
# ពន្ធលើប្រតិបត្តិការធនធានរ៉ែ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើប្រតិបត្តិការធនធានរ៉ែ។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ នៅក្នុងបូរណភាពទឹកដីនិងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។

**ប្រការ៣ .-**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- ធនធានរ៉ែ សំដៅដល់ សារជាតុទាំងឡាយ ទោះបីជាក្នុងទម្រង់រឹង រាវ ឧស្ម័ន ដែលកកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ ត្បូងថ្ម ថ្មូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ និងដីឥដ្ឋ។

២-អាជ្ញាបណ្ណធនធានរ៉ែ សំដៅដល់ លិខិតអនុញ្ញាតដែលផ្ដល់សិទ្ធិឱ្យអ្នកជាប់ពន្ធដោយស្ថាប័ន ដើម្បីធ្វើប្រតិបត្តិការធនធានរ៉ែ។

៣-ប្រតិបត្តិការធនធានរ៉ែ សំដៅដល់ សកម្មភាពទាំងឡាយដែលបានអនុញ្ញាតក្រោមលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណធនធានរ៉ែ។ ប្រតិបត្តិការធនធានរ៉ែត្រូវបានបែងចែកជាដំណាក់កាលបុរេសនា ដំណាក់កាលស្វែងរុករក និងដំណាក់កាលអាជីវកម្មធនធានរ៉ែ។

៤-ដែនអាជ្ញាបណ្ណ សំដៅដល់ ដែនដែលត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនធានរ៉ែនិងជាកម្មវត្ថុនៃអាជ្ញាបណ្ណរួមបញ្ចូលទាំងផ្នែកណាមួយនៃដែនដែលត្រូវបានបោះបង់ចោលដោយអនុលោមទៅតាមអាជ្ញាបណ្ណធនធានរ៉ែនោះ។

៥- ផែនការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញ សំដៅដល់ ផែនការស្តារបរិស្ថានរបស់អ្នកជាប់ពន្ធដែលបានយល់ព្រមដោយស្ថាប័នក្រោមអាជ្ញាបណ្ណធនធានរ៉ែ។ ការស្តារការដ្ឋាន រួមបញ្ចូលទាំងការលុបអណ្តូងរ៉ែ ការដាំដើមឈើឡើងវិញ ការសម្អាតនានាក្នុងដែនអាជ្ញាបណ្ណ។

៦- ចំណាយបុរេសនា សំដៅដល់ ចំណាយដែលទាក់ទិននឹងការស្វែងរុករកដំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញដែលមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដីដើម្បីកំណត់វត្តមានធនធានរ៉ែ។

៧- ចំណាយស្វែងរុករក សំដៅដល់ ចំណាយក្នុងការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញធ្វើតេស្តសន្ទស្សន៍រ៉ែដើម្បីកំណត់សក្តានុពលទំហំគុណភាពបរិមាណព្រមទាំងលទ្ធភាពសេដ្ឋកិច្ចអាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការជីកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត ព្រមទាំងចំណាយរដ្ឋបាលទូទៅ និងចំណាយផ្សេងៗទៀតដែលកើតឡើងនៅក្នុងប្រតិបត្តិការធនធានរ៉ែដើម្បីកំណត់វត្តមាន ទីតាំង បរិមាណ និងគុណភាពនៃជម្រកធនធានរ៉ែ។

៨- ចំណាយអភិវឌ្ឍន៍ សំដៅដល់ ចំណាយដែលបានកើតឡើងដើម្បីអភិវឌ្ឍជម្រកធនធានរ៉ែឱ្យចាប់ផ្តើមដំណើរការផលិតកម្មពាណិជ្ជកម្មបាន មានជាអាទិ៍ ការគូសប្លង់ ការសាងសង់ ការដំឡើងបបនកណ្ឌសម្រាប់ផលិតកម្ម ការធ្វើអណ្តូងផលិតកម្ម ការខួងអណ្តូងផលិតកម្ម ព្រមទាំងសកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរបស់អ្នកជាប់ពន្ធស្របតាមលក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតផលិតកម្មចេញដោយស្ថាប័ន។

៩- ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន សំដៅដល់ ប្រាក់បម្រុងដែលអនុញ្ញាតឱ្យកាត់កងជាមុនសម្រាប់ចំណាយស្តារការដ្ឋានឡើងវិញដែលនឹងត្រូវបានធ្វើឡើងស្របតាមផែនការស្តារការដ្ឋាន។



ﾚ

១០-ចំណាយសរុបដែលបានយល់ព្រមសម្រាប់ស្តារការដ្ឋាន សំដៅដល់ ចំណាយសរុបសម្រាប់ស្តារការដ្ឋានឡើងវិញនៅក្នុងដែនអាជ្ញាបណ្ណដែលបានយល់ព្រមដោយស្ថាប័នតាមផែនការស្តារការដ្ឋានរបស់អ្នកជាប់ពន្ធ ស្របតាមអាជ្ញាបណ្ណឬកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីធនធានរ៉ែ។

១១-ពេលចាប់ផ្តើមផលិតកម្មពាណិជ្ជកម្ម សំដៅដល់ ពេលដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មស្របតាមការកំណត់ក្នុងអាជ្ញាបណ្ណធនធានរ៉ែ។

១២-បំណុល សំដៅដល់ ចំនួនទឹកប្រាក់សរុបដែលអ្នកជាប់ពន្ធជំពាក់ឬត្រូវបង់សង រួមទាំងប្រាក់ខ្ចី ឧបករណ៍ហិរញ្ញវត្ថុ កតិសន្យាហិរញ្ញវត្ថុ ឬឧបករណ៍ហិរញ្ញវត្ថុណាមួយដែលបង្កើតជាការប្រាក់ ការបញ្ចុះតម្លៃ និងបន្ទុកហិរញ្ញវត្ថុដទៃទៀត ដែលអាចកាត់កងបានដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។

១៣-ដើមទុន រួមមាន មូលធនភាគហ៊ុនគ្រប់ប្រភេទ តម្លៃលើសនៃការលក់បណ្ណភាគហ៊ុន មូលធនបម្រុងតាមច្បាប់ លម្អៀងលើសនៃការវាយតម្លៃឡើងវិញនូវទ្រព្យសកម្ម និងប្រាក់ចំណូលរក្សាទុក។

១៤-អ្នកជាប់ពន្ធ សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណធនធានរ៉ែ។

១៥-ស្ថាប័ន សំដៅដល់ ក្រសួងរ៉ែនិងថាមពល ឬស្ថាប័នរាជរដ្ឋាភិបាលដែលទទួលបន្ទុកគ្រប់គ្រងវិស័យរ៉ែ។

**ប្រការ៤ .-**

១- អនុលោមតាមមាត្រា១២៧ នៃច្បាប់ស្តីពីសារពើពន្ធ៖

ក- អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែដូចមានចែងក្នុងប្រការ៣ នៃប្រកាសនេះ ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ៣០ (សាមសិប) ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។

ខ- បន្ថែមលើអត្រាពន្ធដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ ប្រសិនបើអ្នកជាប់ពន្ធមានប្រាក់ចំណូលលើសកម្រិត អ្នកជាប់ពន្ធត្រូវជាប់ពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រាកំណើនតាមថ្នាក់ដោយផ្អែកលើសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតដូចក្នុងតារាងខាងក្រោម៖

| ថ្នាក់ | សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត | អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត |
|---|---|---|
| ១ | ដល់ ១,៣ | 0% |
| ២ | លើសពី ១,៣ ដល់ ១,៦ | ១០% |
| ៣ | លើសពី ១,៦ ដល់ ២ | ២០% |
| ៤ | លើសពី ២ ឡើងទៅ | ៣០% |

២- សមាមាត្រនៃប្រាក់ចំណូលលើសកម្រិតនៃឆ្នាំជាប់ពន្ធចរន្តណាមួយ គឺជាផលចែកនៃទឹកប្រាក់បូកបង្គរនៃចំណូល នឹងទឹកប្រាក់បូកបង្គរនៃចំណាយពីប្រតិបត្តិការធនធានរ៉ែមកទល់នឹងឆ្នាំជាប់ពន្ធចរន្តនោះ។

៣- ការគណនាពន្ធលើប្រាក់ចំណូលលើសកម្រិត ត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

ក- គណនារកមូលដ្ឋានគិតពន្ធលើប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ ដោយយកប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំចរន្ត គុណនឹងផលចែកនៃលម្អៀងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ នឹងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ។

ខ- គណនាពន្ធលើប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ ដោយយកមូលដ្ឋានគិតពន្ធលើប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗដែលបានគណនាតាមវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ គុណនឹងអត្រាពន្ធសម្រាប់ថ្នាក់នោះ។

គ- បូកសរុបប្រាក់ពន្ធលើប្រាក់ចំណូលលើសកម្រិតនៃថ្នាក់នីមួយៗ។

**ឧទាហរណ៍ទី១៖** អ្នកជាប់ពន្ធ មានស្ថានភាពចំណូលចំណាយ ដែលគណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត (សចលក.) ដូចខាងក្រោម៖

| ឆ្នាំជាប់ពន្ធ | ចំណូល | | ចំណាយ | | ចំណូលសុទ្ធ | សចលក. |
|---|---|---|---|---|---|---|
| | ក្នុងឆ្នាំ | បង្គរ | ក្នុងឆ្នាំ | បង្គរ | | |
| | (ក) | (ខ) | (គ) | (ឃ) | (ង)=(ក)-(គ) | (ច)=(ខ)/(ឃ) |
| ២០២០ | ៩ ០០០ ០០០ | ៩ ០០០ ០០០ | ៨ ០០០ ០០០ | ៨ ០០០ ០០០ | ១ ០០០ ០០០ | ១,១៣ |
| ២០២១ | ១១ ០០០ ០០០ | ២០ ០០០ ០០០ | ៥ ០០០ ០០០ | ១៣ ០០០ ០០០ | ៦ ០០០ ០០០ | ១,៥៤ |
| ២០២២ | ១២ ០០០ ០០០ | ៣២ ០០០ ០០០ | ៤ ០០០ ០០០ | ១៧ ០០០ ០០០ | ៨ ០០០ ០០០ | ១,៨៨ |
| ២០២៣ | ១៤ ០០០ ០០០ | ៤៦ ០០០ ០០០ | ៣ ០០០ ០០០ | ២០ ០០០ ០០០ | ១១ ០០០ ០០០ | ២,៣០ |
| ២០២៤ | ១៥ ០០០ ០០០ | ៦១ ០០០ ០០០ | ២ ០០០ ០០០ | ២២ ០០០ ០០០ | ១៣ ០០០ ០០០ | ២,៧៧ |

**ការគណនាពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិត (ពចលក.)៖**

**១- ឆ្នាំជាប់ពន្ធ ២០២០៖**

អ្នកជាប់ពន្ធមានចំណូល ៩ ០០០ ០០០ ដុល្លារអាមេរិក និងចំណាយ ៨ ០០០ ០០០ ដុល្លារអាមេរិក និងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ១,១៣។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធគឺ ១ ០០០ ០០០ ដុល្លារអាមេរិក ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា 0%។

**ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប** **= ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត**

= (១ ០០០ ០០០ x ៣០%) + 0

**= ៣០០ ០០០ ដុល្លារអាមេរិក**

**២- ឆ្នាំជាប់ពន្ធ ២០២១៖**

អ្នកជាប់ពន្ធមានចំណូលបង្គរ ២០ ០០០ ០០០ ដុល្លារអាមេរិក និងចំណាយបង្គរ ១៣ ០០០ ០០០ ដុល្លារអាមេរិក និងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ១,៥៤។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធគឺ ៦ ០០០ ០០០ ដុល្លារអាមេរិក ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា ១០%។

មូលដ្ឋានគិត **ពចលក.** តាមអត្រា ១០% $= ៦\ ០០០\ ០០០ \times \left(\frac{១,៥៤ - ១,៣}{១,៥៤}\right)$

= ៩៣៥ ០៦៥ ដុល្លារអាមេរិក

**ពចលក.** តាមអត្រា ១០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ១០%

= ៩៣៥ ០៦៥ x ១០%

= ៩៣ ៥០៦ ដុល្លារអាមេរិក

**ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប** **= ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត**

= (៦ ០០០ ០០០ x ៣០%) + ៩៣ ៥០៦

**= ១ ៨៩៣ ៥០៦ ដុល្លារអាមេរិក**

**៣- ឆ្នាំជាប់ពន្ធ ២០២២៖**

អ្នកជាប់ពន្ធមានចំណូលបង្គរ ៣២ ០០០ ០០០ ដុល្លារអាមេរិក និងចំណាយបង្គរ ១៧ ០០០ ០០០ ដុល្លារអាមេរិក និងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ១,៨៨។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធគឺ ៨ ០០០ ០០០ ដុល្លារអាមេរិក ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា ១០% ផង និងអត្រា ២០% ផង។

មូលដ្ឋានគិត **ពចលក.** តាមអត្រា ១០% $= ៨\ ០០០\ ០០០ \times \left(\frac{១,៦ - ១,៣}{១,៦}\right)$

= ១ ៥០០ ០០០ ដុល្លារអាមេរិក



lr

**ពចលក.** តាមអត្រា ១០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ១០%

= ១ ៥០០ ០០០ x ១០%

= ១៥០ ០០០ ដុល្លារអាមេរិក

មូលដ្ឋានគិត **ពចលក.** តាមអត្រា ២០% = ៨ ០០០ ០០០ x ( $\frac{១,៨៨ - ១,៦}{១,៨៨}$ )

= ១ ១៩១ ៤៨៩ ដុល្លារអាមេរិក

**ពចលក.** តាមអត្រា ២០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ២០%

= ១ ១៩១ ៤៨៩ x ២០%

= ២៣៨ ២៩៨ ដុល្លារអាមេរិក

**ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត**

= ( ៨ ០០០ ០០០ x ៣០% ) + ( ១៥០ ០០០ + ២៣៨ ២៩៨ )

= **២ ៧៨៨ ២៩៨ ដុល្លារអាមេរិក**

**៤- ឆ្នាំជាប់ពន្ធ ២០២៣៖**

អ្នកជាប់ពន្ធមានចំណូលបង្គរ ៤៦ ០០០ ០០០ ដុល្លារអាមេរិក និងចំណាយបង្គរ ២០ ០០០ ០០០ ដុល្លារអាមេរិក និងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ២,៣០។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធគឺ ១១ ០០០ ០០០ ដុល្លារអាមេរិក ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា ១០% ផង អត្រា ២០% ផង និងអត្រា ៣០% ផង។

មូលដ្ឋានគិត **ពចលក.** តាមអត្រា ១០% = ១១ ០០០ ០០០ x ( $\frac{១,៦ - ១,៣}{១,៦}$ )

= ២ ០៦២ ៥០០ ដុល្លារអាមេរិក

**ពចលក.** តាមអត្រា ១០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ១០%

= ២ ០៦២ ៥០០ x ១០%

= ២០៦ ២៥០ ដុល្លារអាមេរិក

មូលដ្ឋានគិត **ពចលក.** តាមអត្រា ២០% = ១១ ០០០ ០០០ x ( $\frac{២ - ១,៦}{២}$ )

= ២ ២០០ ០០០ ដុល្លារអាមេរិក

**ពចលក.** តាមអត្រា ២០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ២០%

= ២ ២០០ ០០០ x ២០%

= ៤៤០ ០០០ ដុល្លារអាមេរិក

មូលដ្ឋានគិត **ពចលក.** តាមអត្រា ៣០% = ១១ ០០០ ០០០ x ( $\frac{២,៣០ - ២}{២,៣០}$ )

= ១ ៤៣៤ ៧៨៣ ដុល្លារអាមេរិក

**ពចលក.** តាមអត្រា ៣០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ៣០%

= ១ ៤៣៤ ៧៨៣ x ៣០%

= ៤៣០ ៤៣៥ ដុល្លារអាមេរិក

**ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត**

= ( ១១ ០០០ ០០០ x ៣០% ) + ( ២០៦ ២៥០ + ៤៤០ ០០០ + ៤៣០ ៤៣៥ )

= **៤ ៣៧៦ ៦៨៥ ដុល្លារអាមេរិក**



4

**ប្រការ៥ ._**

អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ ត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់ត្រឹមតែចំនួនដែលគណនាតាមវិធានសមាមាត្រនៃបំណុល ៣ (បី) ធៀបនឹងដើមទុន ១ (មួយ) ទោះបីអ្នកជាប់ពន្ធខ្ចីបុលប្រាក់ដើម្បីប្រកបអាជីវកម្មរបស់ខ្លួនក្នុងកម្រិតណាក៏ដោយ។

**ឧទាហរណ៍ទី២៖** អ្នកជាប់ពន្ធ ក ធ្វើប្រតិបត្តិការធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដើមទុនចំនួន ២០ ០០០ ០០០ ដុល្លារអាមេរិក។ ដោយខ្វះដើមទុន អ្នកជាប់ពន្ធបានខ្ចីប្រាក់ចំនួន ៨០ ០០០ ០០០ ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ៥% ក្នុងមួយឆ្នាំ។ ដូចនេះ ចំណាយការប្រាក់ដែលអ្នកជាប់ពន្ធ ក ត្រូវបង់ឱ្យម្ចាស់បំណុលក្នុងមួយឆ្នាំស្មើនឹង ៨០ ០០០ ០០០ x ៥% = ៤ ០០០ ០០០ ដុល្លារអាមេរិក។

ក្នុងការគណនាប្រាក់ចំណូលជាប់ពន្ធ អ្នកជាប់ពន្ធ ក មិនអាចកាត់កងចំណាយការប្រាក់ដែលបង់ឱ្យម្ចាស់បំណុលទាំងស្រុងចំនួន ៤ ០០០ ០០០ ដុល្លារអាមេរិក បានទេ។ អ្នកជាប់ពន្ធត្រូវគណនាការប្រាក់ដែលអនុញ្ញាតឱ្យកាត់កងតាមវិធានសមាមាត្របំណុល ៣ ធៀបនឹងដើមទុន ១ ដូចខាងក្រោម៖

| | | |
|---|---|---|
| មូលដ្ឋានគិតការប្រាក់ដើម្បីកាត់កង | = | ដើមទុនរបស់អ្នកជាប់ពន្ធ x ៣ |
| | = | ២០ ០០០ ០០០ x ៣ |
| | = | ៦០ ០០០ ០០០ ដុល្លារអាមេរិក |
| **ចំនួនការប្រាក់ដែលអនុញ្ញាតឱ្យកាត់កង** | **=** | **មូលដ្ឋានគិតការប្រាក់ដើម្បីកាត់កង x អត្រាការប្រាក់** |
| | = | ៦០ ០០០ ០០០ x ៥% |
| | = | **៣ ០០០ ០០០ ដុល្លារអាមេរិក** |

ដោយឡែកចំពោះពន្ធកាត់ទុកដែលមានចែងក្នុងមាត្រា២៥ ឬមាត្រា២៦ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវអនុវត្តលើចំណាយការប្រាក់ជាក់ស្តែងចំនួន ៤ ០០០ ០០០ ដុល្លារអាមេរិក ដែលបានបង់ឱ្យម្ចាស់បំណុល។

**ប្រការ៦ ._**

ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាននិងចំណាយស្តារការដ្ឋានជាក់ស្តែងដូចមានចែងក្នុងមាត្រា១៣០ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវបានកំណត់ដូចតទៅ៖

១- ប្រសិនបើអ្នកជាប់ពន្ធមានផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័នទីកប្រាក់ដែលបានតម្រូវឱ្យអ្នកជាប់ពន្ធបង់ចូលមូលនិធិសម្រាប់ចំណាយស្តារការដ្ឋាន ត្រូវបានចាត់ទុកជាប្រាក់បម្រុងសម្រាប់ចំណាយបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងនេះ ត្រូវបានអនុញ្ញាតជាសំវិធានធន និងត្រូវបានអនុញ្ញាតឱ្យកាត់កងក្នុងឆ្នាំជាប់ពន្ធដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធគ្មានផែនការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញដែលបានយល់ព្រមដោយស្ថាប័នទេ ប្រាក់បម្រុងតាមកថាខណ្ឌនេះ មិនត្រូវបានអនុញ្ញាតឡើយ។

២- ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន ត្រូវបានគណនាដោយផ្អែកទៅតាមចំណាយសរុបដែលបានយល់ព្រមដោយស្ថាប័នសម្រាប់បិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ។ ប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋានក្នុងឆ្នាំនីមួយៗ និងឆ្នាំដែលប្រាក់បម្រុងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាត់កង ត្រូវកំណត់តាមផែនការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញ។

៣-ប្រសិនបើចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញមានចំនួនលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

**ឧទាហរណ៍ទី៣៖** អ្នកជាប់ពន្ធធ្វើប្រតិបត្តិការធនធានរ៉ែក្នុងដែនអាជ្ញាបណ្ណមួយ ដែលមានអាយុកាលរំពឹងទុកនៃផលិតកម្មចំនួន ៥ឆ្នាំ។ ទឹកប្រាក់បម្រុងសម្រាប់ស្តារការដ្ឋានដែលបានយល់ព្រមដោយស្ថាប័នមានចំនួន ៥០០ ០០០ ដុល្លារអាមេរិក។ ចំនួនទឹកប្រាក់បម្រុងសម្រាប់ស្តារការដ្ឋាននេះ ត្រូវបានអនុញ្ញាតឱ្យកាត់កងចាប់ពីឆ្នាំជាប់ពន្ធទី១ រហូតដល់ឆ្នាំជាប់ពន្ធទី៥ ដោយក្នុងមួយឆ្នាំៗមានចំនួន ១០០ ០០០ ដុល្លារអាមេរិក។ ក្នុងការស្តារការដ្ឋានជាក់ស្តែង អ្នកជាប់ពន្ធ



ꟿ

បានចំណាយទឹកប្រាក់សរុបចំនួន ៥៤០ ០០០ ដុល្លារអាមេរិក ដែលលើសពីទឹកប្រាក់បម្រុងចំនួន ៤០ ០០០ ដុល្លារអាមេរិក។ ទឹកប្រាក់លម្អៀងនេះត្រូវបានអនុញ្ញាតជាចំណាយកាត់កងបន្ថែមនៅក្នុងឆ្នាំជាប់ពន្ធ។

៤- ប្រសិនបើនៅចុងបញ្ចប់នៃការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញ ចំណាយសរុបជាក់ស្តែងនៃការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញមានចំនួនតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយស្តារការដ្ឋាន ចំនួនលម្អៀងនោះ ត្រូវគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលការបិទការដ្ឋានរ៉ែនិងការស្តារបរិស្ថានឡើងវិញនោះបានបញ្ចប់។

**ឧទាហរណ៍ទី៤៖** អ្នកជាប់ពន្ធធ្វើប្រតិបត្តិការធនធានរ៉ែក្នុងដែនអាជ្ញាបណ្ណមួយ ដែលមានអាយុកាលរំពឹងទុកនៃផលិតកម្មចំនួន ៥ឆ្នាំ។ ទឹកប្រាក់បម្រុងសម្រាប់ស្តារការដ្ឋានដែលបានយល់ព្រមដោយស្ថាប័នមានចំនួន ៥០០ ០០០ ដុល្លារអាមេរិក។ ចំនួនទឹកប្រាក់បម្រុងសម្រាប់ស្តារការដ្ឋាននេះ ត្រូវបានអនុញ្ញាតឱ្យកាត់កងចាប់ពីឆ្នាំជាប់ពន្ធទី១ រហូតដល់ឆ្នាំជាប់ពន្ធទី៥ ដោយក្នុងមួយឆ្នាំៗមានចំនួន ១០០ ០០០ ដុល្លារអាមេរិក។ នៅពេលការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញត្រូវបានបញ្ចប់ អ្នកជាប់ពន្ធបានចំណាយលើការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញជាក់ស្តែងចំនួន ៤៥០ ០០០ ដុល្លារអាមេរិក ដែលតិចជាងទឹកប្រាក់បម្រុងចំនួន ៥០ ០០០ ដុល្លារអាមេរិក។ ទឹកប្រាក់លម្អៀងនេះ ត្រូវគិតបញ្ចូលទៅក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលការបិទការដ្ឋានរ៉ែនិងស្តារបរិស្ថានឡើងវិញនោះបានបញ្ចប់។

**ប្រការ៧ .-**

វិធីរំលស់ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមមាត្រា១៣២ នៃច្បាប់ស្តីពីសារពើពន្ធ។ រំលស់ស្មើភាគ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនានិងចំណាយស្វែងរុករក តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ ៥ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

ខ- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ ៧ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

គ- ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវធ្វើការកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែ ដោយមិនត្រូវឱ្យលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះឡើយ។

ឃ- ក្នុងករណីអ្នកជាប់ពន្ធមានគម្រោងអភិវឌ្ឍន៍ដែលមានរយៈពេលតិចជាង ១ឆ្នាំ ចំណាយអភិវឌ្ឍន៍នេះអាចបញ្ចូលទៅធ្វើរំលស់ក្នុងចំណាយបុរេសនា និងចំណាយស្វែងរុករក។

ង- អាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មត្រូវកំណត់ដោយអ្នកជាប់ពន្ធ ដែលមានការយល់ព្រមពីស្ថាប័នដូចដែលបានកំណត់ក្នុងអាជ្ញាបណ្ណធនធានរ៉ែ។

**ឧទាហរណ៍ទី៥៖** អ្នកជាប់ពន្ធធ្វើប្រតិបត្តិការធនធានរ៉ែក្នុងដែនអាជ្ញាបណ្ណមួយ ដែលអាយុកាលរំពឹងទុកដំបូងនៃផលិតកម្មពាណិជ្ជកម្មមានរយៈពេល ៤ឆ្នាំ។ នៅដើមឆ្នាំទី៤ អ្នកជាប់ពន្ធបានសម្រេចចិត្តធ្វើការកែសម្រួលអាយុកាលរំពឹងទុកនៃមធ្យោបាយផលិតកម្មពាណិជ្ជកម្មរហូតដល់រយៈពេល ៥ឆ្នាំ។

| ចំណាយ | សរុប | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ |
|---|---|---|---|---|---|---|
| ស្វែងរុករក | ៤០០ | ១០០ | ១០០ | ១០០ | ៥០ | ៥០ |
| | ១០០% | ២៥% | ២៥% | ២៥% | ១២,៥% | ១២,៥% |
| អភិវឌ្ឍន៍ | ៨០០ | ២០០ | ២០០ | ២០០ | ១០០ | ១០០ |
| | ១០០% | ២៥% | ២៥% | ២៥% | ១២,៥% | ១២,៥% |

**ឧទាហរណ៍ទី៦៖** អ្នកជាប់ពន្ធធ្វើប្រតិបត្តិការធនធានរ៉ែក្នុងដែនអាជ្ញាបណ្ណមួយ ដែលអាយុកាលរំពឹងទុកដំបូងនៃផលិតកម្មពាណិជ្ជកម្មមានរយៈពេល ៥ឆ្នាំ។ នៅដើមឆ្នាំទី៣ អ្នកជាប់ពន្ធបានសម្រេចចិត្តធ្វើការកែសម្រួលអាយុកាលរំពឹងទុកនៃមធ្យោបាយផលិតកម្មពាណិជ្ជកម្មថយចុះមកត្រឹម ៤ឆ្នាំ។

| ចំណាយ | សរុប | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ |
|---|---|---|---|---|---|---|
| ស្វែងរុករក | ៤០០ | ៨០ | ៨០ | ១២០ | ១២០ | ០ |
| | ១០០% | ២០% | ២០% | ៣០% | ៣០% | ០% |
| អភិវឌ្ឍន៍ | ៨០០ | ១៦០ | ១៦០ | ២៤០ | ២៤០ | ០ |
| | ១០០% | ២០% | ២០% | ៣០% | ៣០% | ០% |

២-ចំពោះទ្រព្យរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ ដែលបានទិញឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងដែនអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ទ្រព្យរូបីទាំងនោះតាមវាក្យខណ្ឌ ក ដល់វាក្យខណ្ឌ ឃ នៃកថាខណ្ឌទី១ នៃមាត្រា១៣ នៃច្បាប់ស្តីពីសារពើពន្ធ។

៣-ចំពោះទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ អ្នកជាប់ពន្ធត្រូវធ្វើរំលស់តាមមាត្រា១៤ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ៨ .-**

ពេលធ្វើរំលស់ ត្រូវបានកំណត់ដូចខាងក្រោម ៖

១-អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ ដែលបានកើតឡើងមុនពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងនៅដំណាច់ឆ្នាំជាប់ពន្ធ ដែលអ្នកជាប់ពន្ធចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងដែនអាជ្ញាបណ្ណ។

២-ក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងដែនអាជ្ញាបណ្ណ ប្រសិនបើអ្នកជាប់ពន្ធធ្វើបុរេសនា ឬស្វែងរុករកឬសាងសង់បន្តនូវមធ្យោបាយផលិតកម្មដទៃទៀតក្រោមគម្រោងអភិវឌ្ឍន៍ក្នុងដែនអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមពេលដូចខាងក្រោម៖

- ក- នៅដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ ចំពោះចំណាយបុរេសនា ឬចំណាយស្វែងរុករក ទៅតាមលំដាប់ឆ្នាំដែលចំណាយនោះបានកើតឡើង។
- ខ- នៅដំណាច់ឆ្នាំជាប់ពន្ធដែលមធ្យោបាយផលិតកម្មនីមួយៗត្រូវបានដាក់ឱ្យប្រើប្រាស់ ចំពោះចំណាយអភិវឌ្ឍន៍។

៣-រំលស់ត្រូវធ្វើដាច់ដោយឡែកៗពីគ្នា សម្រាប់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ ស្របតាមកថាខណ្ឌទី១ នៃប្រការ៧ នៃប្រកាសនេះ ហើយត្រូវបូកសរុបបញ្ចូលគ្នាសម្រាប់កាត់កងក្នុងឆ្នាំជាប់ពន្ធ។

៤-ចំពោះទ្រព្យរូបី និងទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញ ឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងដែនអាជ្ញាបណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់។

៥-ប្រសិនបើប្រតិបត្តិការធនធានរ៉ែត្រូវបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធណាមួយ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយនូវតម្លៃទ្រព្យសកម្មដែលនៅសេសសល់ទាំងអស់ រួមបញ្ចូលទាំងចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍នៅក្នុងឆ្នាំជាប់ពន្ធ។

**ឧទាហរណ៍ទី៧៖** អ្នកជាប់ពន្ធធ្វើប្រតិបត្តិការធនធានរ៉ែក្នុងដែនអាជ្ញាបណ្ណមួយដែលមានមធ្យោបាយផលិតកម្មចំនួន ២ ក្នុងគម្រោងអភិវឌ្ឍន៍តែមួយដូចខាងក្រោម៖

- មធ្យោបាយផលិតកម្មទី១ មានអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរយៈពេល ៦ឆ្នាំ និងបានចំណាយស្វែងរុករកមានចំនួន ៥ ០០០ ០០០ ដុល្លារអាមេរិក និងចំណាយអភិវឌ្ឍន៍ចំនួន ១២ ០០០ ០០០ ដុល្លារអាមេរិក



ﾠ

- មធ្យោបាយផលិតកម្មទី២បានចាប់ផ្តើមនៅឆ្នាំទី៤ដែលមានអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរយៈពេល ៧ឆ្នាំ និងចាប់ផ្តើមផលិតកម្មពាណិជ្ជកម្មនៅឆ្នាំទី៥។ ចំណាយស្វែងរុករកមានចំនួន ១០ ០០០ ០០០ ដុល្លារអាមេរិក និងចំណាយអភិវឌ្ឍន៍ចំនួន ២១ ០០០ ០០០ ដុល្លារអាមេរិក។

| ចំណាយ | រយៈពេលនៃការធ្វើរំលស់(ឆ្នាំ) | អាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្ម | សរុប (លាន) | ឆ្នាំទី | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| គម្រោងអភិវឌ្ឍន៍ទី១ | | | | | | | | | | | | | | | |
| ស្វែងរុករក | ៥ | ៦ | ៥ | ១ | ១ | ១ | ១ | ១ | | | | | | | |
| អភិវឌ្ឍន៍ | ៦ | | ១២ | ២ | ២ | ២ | ២ | ២ | ២ | | | | | | |
| គម្រោងអភិវឌ្ឍន៍ទី២ | | | | | | | | | | | | | | | |
| ស្វែងរុករក | ៥ | ៧ | ១០ | | | | ២ | ២ | ២ | ២ | ២ | | | | |
| អភិវឌ្ឍន៍ | ៧ | | ២១ | | | | | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | |
| **សរុប** | | | | ៣ | ៣ | ៣ | ៥ | ៨ | ៧ | ៥ | ៥ | ៣ | ៣ | ៣ | |

**ប្រការ៩ ._**

ក្នុងករណីមានការផ្ទេរមួយផ្នែកឬទាំងស្រុងនៃអត្ថប្រយោជន៍ដែលជាសិទ្ធិឬចំណែកក្នុងអាជ្ញាបណ្ណធនធានរ៉ែ តាមរូបភាពលក់ទិញ ដោះដូរ ឬធ្វើអំណោយ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ និងបុគ្គលជាអ្នកទទួលបន្ត ត្រូវអនុវត្តដូចខាងក្រោម៖

១- អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ ត្រូវកត់ត្រាចំណូលដែលទទួលបានពីការផ្ទេរអត្ថប្រយោជន៍ក្នុងអាជ្ញាបណ្ណធនធានរ៉ែ ជាចំណូលពីប្រតិបត្តិការធនធានរ៉ែ ដែលជាកម្មវត្ថុនៃពន្ធលើប្រាក់ចំណូលស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ។

២- បុគ្គលជាអ្នកទទួលបន្តត្រូវ៖

ក- បន្តអនុវត្តកាតព្វកិច្ចសារពើពន្ធពីអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ ចំពោះអត្ថប្រយោជន៍ដែលជាសិទ្ធិឬចំណែកដែលបានទទួល។

ខ- បន្តធ្វើរំលស់ទ្រព្យរូបី ទ្រព្យអរូបី ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធាន និងនីតិវិធី និងមូលដ្ឋានដែលអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរបានធ្វើរំលស់កន្លងមក។

គ- ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងអាជ្ញាបណ្ណធនធានរ៉ែ មានតម្លៃលើសពីតម្លៃពិតគណនេយ្យ តម្លៃលម្អៀងត្រូវបានចាត់ទុកជាមូលនិធិពាណិជ្ជកម្ម។ បុគ្គលជាអ្នកទទួលបន្ត ត្រូវធ្វើរំលស់មូលនិធិពាណិជ្ជកម្មនេះ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ ឬ ៧ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

ឃ-ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងអាជ្ញាបណ្ណធនធានរ៉ែ មានតម្លៃតិចជាងតម្លៃពិតគណនេយ្យ តម្លៃលម្អៀងនោះត្រូវបានចាត់ទុកជាចំណូល។ បុគ្គលជាអ្នកទទួលបន្ត ត្រូវកត់ត្រាជាចំណូលសម្រាប់ឆ្នាំបន្តបន្ទាប់ដោយបែងចែកចំណូលទាំងនេះតាមសមាមាត្រនៃអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ ឬ ៧ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

**ប្រការ១០ ._**

១- ចំណាយដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែនៅក្នុងដែនអាជ្ញាបណ្ណណាមួយ សម្រាប់ឆ្នាំជាប់ពន្ធណាមួយត្រូវបានអនុញ្ញាតឱ្យកាត់កងតែពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការធនធានរ៉ែ ក្នុងដែនអាជ្ញាបណ្ណនៃឆ្នាំជាប់ពន្ធនោះប៉ុណ្ណោះ។

២- ចំណាយដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែនៅក្នុងដែនអាជ្ញាបណ្ណណាមួយ មិនអាចកាត់កងពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការធនធានរ៉ែនៅក្នុងដែនអាជ្ញាបណ្ណដទៃទៀតទេ ហើយក៏មិនអាចកាត់កងពីប្រាក់ចំណូលដុលសរុបពីប្រភពផ្សេងទៀតក្រៅពីប្រតិបត្តិការធនធានរ៉ែឡើយ។

**ប្រការ១១ ._**

១-ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំណាយសរុបដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែនៅក្នុងដែនអាជ្ញាបណ្ណ លើសពីចំណូលដុលសរុបដែលនាំឱ្យមានលទ្ធផលខាតបង់ ការខាតបង់ត្រូវបានអនុញ្ញាតឱ្យយោងទៅកាត់កងពីប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធបន្ទាប់។

២-ប្រសិនបើប្រាក់ចំណូលជាប់ពន្ធនៃឆ្នាំជាប់ពន្ធបន្ទាប់ មិនគ្រប់គ្រាន់សម្រាប់កាត់កងការយោងខាតជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវបានអនុញ្ញាតឱ្យយោងទៅមុខរហូតដល់ ១០ឆ្នាំ ដោយមិនគិតថាអ្នកជាប់ពន្ធមានប្រាក់ចំណូលជាប់ពន្ធ ឬខាតបង់នោះទេ។ ប្រសិនបើក្នុងរយៈពេល ១០ឆ្នាំ ចំណែកនៃការយោងការខាតបង់មិនអាចកាត់កងអស់ជាស្ថាពរទេ ចំណែកខាតបង់ដែលនៅសេសសល់នោះមិនត្រូវបានអនុញ្ញាតឱ្យកាត់កងទៀតឡើយ។ ក្នុងករណីដែលមានការខាតបង់លើសពី ១ឆ្នាំ ការយោងការខាតបង់ត្រូវអនុវត្តតាមលំដាប់ឆ្នាំដែលការខាតបង់ទាំងឡាយបានកើតឡើង។

៣-ការខាតបង់ដែលកើតមានឡើងនៅក្នុងដែនអាជ្ញាបណ្ណណាមួយ មិនអាចយោងយកទៅកាត់កងក្នុងដែនអាជ្ញាបណ្ណដទៃទៀតឡើយ។

**ឧទាហរណ៍ទី៨៖**

- ក្នុងឆ្នាំជាប់ពន្ធទី១ អ្នកជាប់ពន្ធមានលទ្ធផលខាតចំនួន ២ ០០០ ០០០ ដុល្លារអាមេរិក
- ក្នុងឆ្នាំជាប់ពន្ធទី២ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ១០០ ០០០ ដុល្លារអាមេរិក។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ១០០ ០០០ ដុល្លារអាមេរិកនេះ មកកាត់កងជាមួយការខាតបង់ក្នុងឆ្នាំជាប់ពន្ធទី១។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការខាតបង់ក្នុងឆ្នាំជាប់ពន្ធទី១ ចំនួន ១ ៩០០ ០០០ ដុល្លារអាមេរិក ដើម្បីយោងទៅឆ្នាំបន្ទាប់
- ក្នុងឆ្នាំជាប់ពន្ធទី៣ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ៣០០ ០០០ ដុល្លារអាមេរិក។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ៣០០ ០០០ ដុល្លារអាមេរិកនេះ មកកាត់កងជាមួយការខាតបង់ក្នុងឆ្នាំជាប់ពន្ធទី១ ដែលនៅសល់។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការយោងខាតក្នុងឆ្នាំជាប់ពន្ធទី១ ចំនួន ១ ៦០០ ០០០ ដុល្លារអាមេរិក
- ក្នុងឆ្នាំជាប់ពន្ធទី៤ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ៥០០ ០០០ ដុល្លារអាមេរិក។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ៥០០ ០០០ ដុល្លារអាមេរិកនេះ មកកាត់កងជាមួយការយោងខាតក្នុងឆ្នាំជាប់ពន្ធទី១ ដែលនៅសល់។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការយោងខាតក្នុងឆ្នាំជាប់ពន្ធទី១ ចំនួន ១ ១០០ ០០០ ដុល្លារអាមេរិក
- ក្នុងឆ្នាំជាប់ពន្ធទី៥ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ៤០០ ០០០ ដុល្លារអាមេរិក។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ៤០០ ០០០ ដុល្លារអាមេរិកនេះ មកកាត់កងជាមួយការយោងខាតក្នុងឆ្នាំជាប់ពន្ធទី១ ដែលនៅសល់។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការយោងខាតក្នុងឆ្នាំជាប់ពន្ធទី១ ចំនួន ៧០០ ០០០ ដុល្លារអាមេរិក
- ក្នុងឆ្នាំជាប់ពន្ធទី៦ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ២០០ ០០០ ដុល្លារអាមេរិក។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ២០០ ០០០ ដុល្លារអាមេរិកនេះ មកកាត់កងជាមួយការយោងខាតក្នុងឆ្នាំជាប់ពន្ធទី១ ដែលនៅសល់។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការខាតបង់ក្នុងឆ្នាំជាប់ពន្ធទី១ ចំនួន ៥០០ ០០០ ដុល្លារអាមេរិក ដែលការខាតបង់នេះមិនអាចយោងទៅឆ្នាំបន្ទាប់បានឡើយ។

**ប្រការ១២ ._**

១- អ្នកជាប់ពន្ធមានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែតាមអត្រា ១ (មួយ) ភាគរយ នៃផលរបរដែលសម្រេចបានក្នុងខែមុន ដោយគិតរួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

២-នៅពេលដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ប្រសិនបើប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់ក្នុងឆ្នាំជាប់ពន្ធណាមួយច្រើនជាងបំណុលពន្ធលើប្រាក់ចំណូល ចំនួនលម្អៀងត្រូវបានអនុញ្ញាតជាឥណទានសម្រាប់ប្រើប្រាស់ជាប្រាក់រំដោះពន្ធលើប្រាក់ចំណូលសម្រាប់ខែបន្តបន្ទាប់ ក្រោយពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធនោះ។

៣-នៅពេលបញ្ចប់ប្រតិបត្តិការធនធានរ៉ែ ប្រសិនបើមាននៅសល់ឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូល អ្នកជាប់ពន្ធអាចធ្វើការស្នើសុំទៅរដ្ឋបាលសារពើពន្ធ ឱ្យបង្វិលសងនូវឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលនៅសល់នោះ។

**ប្រការ១៣ .-**

១-អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធអាករប្រចាំខែ ប្រចាំឆ្នាំ ដាច់ដោយឡែកពីគ្នា ជូនរដ្ឋបាលសារពើពន្ធ ទៅតាមការកំណត់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

២-ប្រតិបត្តិករដែលជាតំណាងអ្នកជាប់ពន្ធទាំងអស់ក្នុងដែនអាជ្ញាបណ្ណ ត្រូវផ្តល់របាយការណ៍និងឯកសារនានានៃប្រតិបត្តិការអាជីវកម្មក្នុងដែនអាជ្ញាបណ្ណតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ។

**ប្រការ១៤ .-**

អ្នកជាប់ពន្ធអាចស្នើសុំការអនុញ្ញាតពីរដ្ឋបាលសារពើពន្ធ ដើម្បីប្រើប្រាស់ភាសាអង់គ្លេស និងប្រើប្រាស់រូបិយប័ណ្ណជាប្រាក់ដុល្លារអាមេរិក សម្រាប់កត់ត្រាបញ្ជិកាគណនេយ្យ របាយការណ៍ និងឯកសារនានាដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែ។

**ប្រការ១៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហ ១៤កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ១៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ